ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងកន្លែងនៃសាងសហគមន៍ ត្រាំពែរ
# និង ឯកសារពាក់ព័ន្ធ

## បញ្ជីអត្ថបទ

១- កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

២- ផែនទីកន្លែងនេសាទសហគមន៍

៣- បញ្ជីឈ្មោះសមាជិក គណៈកម្មការ និងរចនាសម្ព័ន្ធ

៤- លក្ខន្តិកៈសហគមន៍នេសាទ

៥- បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

៦- សេចក្តីថ្លែងការណ៍

៧- ឯកសារពាក់ព័ន្ធផ្សេងៗទៀត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ត្រាំពែរ

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | : | ត្រាំពែរ |
| ភូមិ | : | ត្រាំពែរ |
| ឃុំ | : | ស្នាមព្រះ |
| ស្រុក | : | បាកាន |
| ខេត្ត | : | ពោធិ៍សាត់ |

# កិច្ចព្រមព្រៀង
# កន្លែងនេសាទសហគមន៍

**រវាង**

នាយខណ្ឌរដ្ឋបាលជលផល ខេត្តពោធិ៍សាត់ ជាតំណាងស្របច្បាប់នៃរដ្ឋបាលជលផល មានអាស័យដ្ឋាននៅៈ ភូមិពាលញែក២ ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ទូរស័ព្ទលេខ ០៥២ ៩៥១ ៤៩១ អ៊ីម៉ែលsonglypursat@online.com.kh ទូរសារលេខ ០៥២ ៩៥១ ៤៩១ ហៅថា " ភាគី **ក** " ។

**និង**

ប្រធានគណៈកម្មការសហគមន៏នេសាទ ត្រាំពែរ ជាតំណាងស្របច្បាប់ឱ្យសហគមន៏នេសាទ ដែលមានអាសយដ្ឋានស្ថិតនៅៈ ភូមិ ត្រាំពែរ ឃុំ ស្នាមព្រះ ទូរស័ព្ទលេខ ០៩២ ៦២២ ៤៦៧ ហៅថា " ភាគី **ខ** " ។

ភាគីទាំងពីរបានឯកភាពគ្នាចុះកិច្ចព្រមព្រៀងតាមលក្ខខណ្ឌដូចខាងក្រោម ÷

**ប្រការ ១.–**

ភាគី **ក** ប្រគល់ដែននេសាទដែលជាទ្រព្យសម្បត្តិរបស់រដ្ឋឱ្យភាគី **ខ** ធ្វើការគ្រប់គ្រង ការពារ អភិរក្ស អភិវឌ្ឍន៏ និងប្រើប្រាស់ធនធានជលផលរយៈពេល ៣ ឆ្នាំ ចាប់ពីថ្ងៃទី...19.....ខែ...ឧសភា...ឆ្នាំ..2007......រហូតដល់ថ្ងៃទី ....19......ខែ...ឧសភា....ឆ្នាំ...2010..............ដោយធានានូវចីរភាពតាមរយៈការរៀបចំសហគមន៏នេសាទ ។

**ប្រការ ២.–**

ដែននេសាទនេះមានឈ្មោះថា "កន្លែងនេសាទសហគមន៏ ត្រាំពែរ" ដែលលាតសន្ធឹងនៅក្នុង : –

ភូមិ ត្រាំពែរ ឃុំ ស្នាមព្រះ

ស្រុក បាកាន ខេត្ត ពោធិ៍សាត់

មាននិយាមកាដូចខាងក្រោមៈ

GCP01(X: 376375, Y: 1403406) ចំនុចប្រសព្វអូរនឹងទំនប់ចាកចេញ, GCP02(X: 376907, Y: 1406770) ចុងបឹងប្រស្នឹងខាងជើង, GCP03(X: 377571, Y: 1414388) ដីរចោលត្បាល់, GCP04(X: 379823, Y: 1414301) ចុងបឹងព្រួចខាងត្បូង, GCP05(X: 380184, Y: 1411634) ផ្លូវបំបែកចូលបឹងកក់, GCP06(X: 379678, Y: 1408656) ចុងបឹងអន្ទ្រោមក្លែងខាងកើត, GCP07(X: 378697, Y: 1405306) កែងផ្លូវស្រះរួម GCP08(X: 379739, Y: 1405579) ទំនប់អំពាក់, GCP09(X: 379390, Y: 1403328) ផ្លូវកែងផ្ទះតាបូ GCP10(X: 378366, Y: 1401890) ផ្លូវកែងត្រាំពែរ

ដូចផែនទីដែលបានភ្ជាប់មកជាមួយ ។

**ប្រការ ៣.**

ភាគី ក ត្រូវបំពេញភារកិច្ចជាអ្នកជួយសម្របសម្រួល ផ្តល់បច្ចេកទេស ទប់ស្កាត់បទល្មើស តាមដាន និងត្រួតពិនិត្យលើការរៀបចំ និងការប្រព្រឹត្តទៅរបស់សហគមន៍នេសាទដូចមានចែងនៅក្នុងមាត្រា ២៣ នៃអនុក្រឹត្យ លេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ។

**ប្រការ ៤.**

ភាគី ខ ត្រូវរៀបចំ÷

- កន្លែងអភិរក្សព្រៃលិចទឹក
- កន្លែងអភិរក្សត្រីមេពូជ
- កន្លែងអភិរក្សជីវចំរុះ
- ស្តារប្រឡាយ ព្រែក បឹង ស្រះ
- ដាំព្រៃលិចទឹក
- ធ្វើវារីវប្បកម្ម
- បញ្ជូនសមាជិកសហគមន៍ដើម្បីរៀនសូត្រនូវបច្ចេកទេសផលិតពូជត្រី
- ការងារអភិវឌ្ឍន៍ផ្សេងៗទៀត ។

**ប្រការ ៥.**

ភាគី ខ ត្រូវរៀបចំប្រជុំពិភាក្សាអំពីទំហំ ចំនួន ប្រវែង និងប្រភេទឧបករណ៍នេសាទ ដែលអនុញ្ញាតឱ្យប្រើប្រាស់នៅក្នុងកន្លែងនេសាទសហគមន៍ ឱ្យសមស្របតាមស្ថានភាពភូមិសាស្ត្រ និងពេលវេលា ផ្អែកតាមច្បាប់ស្តីពីជលផល និងលិខិតបង្គាប់គតិយុត្តិនានាដែលពាក់ព័ន្ធ។

**ប្រការ ៦.**

ភាគី ខ មានកាតព្វកិច្ចថែរក្សាការពារធនធានធម្មជាតិដូចខាងក្រោម÷

- ការពារព្រៃលិចទឹកដែលមានស្រាប់ឱ្យបានគង់វង្ស ចាត់វិធានការទប់ស្កាត់ និងបង្ការភ្លើងឆេះព្រៃ
- រក្សា និងការពារដីទំនាបលិចទឹកសម្រាប់ដាំព្រៃលិចទឹកឡើងវិញ
- លែងទៅក្នុងធម្មជាតិវិញនូវវារីសត្វដែលកំពុងរងគ្រោះថ្នាក់ជិតផុតពូជ នៅពេលដែលធ្វើនេសាទបាន
- ការពារសត្វព្រៃគ្រប់ប្រភេទនៅក្នុងដែននេសាទ ឬព្រៃលិចទឹក។

**ប្រការ ៧.**

ភាគី ខ មិនត្រូវធ្វើសកម្មភាពដែលបង្កឱ្យខូចដែននេសាទ ឬគ្រោះថ្នាក់ដល់ធនធានជលផលដូចខាងក្រោម÷

- ចាប់នូវធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ ដូចមានចែងក្នុងប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចជាផ្សោតជាដើម
- លើកទំនប់ លុប ឬជីក បឹង ព្រែក ប្រឡាយ រណ្តៅ បៀ ស្រះ ដែលពុំមានការអនុញ្ញាតពីស្ថាប័នជំនាញ
- កាប់ ឆ្ការ គាស់ រាន ឈូសឆាយព្រៃលិចទឹក ក្នុងគោលបំណងហ៊ុំព័ទ្ធយកដីជាកម្មសិទ្ធិ ឬវាតដី

ធ្វើស្រែចំការ ឬគោលបំណងផ្សេងៗឡើយ
- ធ្វើនេសាទ កាប់ព្រៃ ឬអុសក្នុងកន្លែងអភិរក្សជលផល ក្នុងកន្លែងនេសាទសហគមន៍
- ប្រើប្រាស់ឧបករណ៍ហាមឃាត់ ជាពិសេសឧបករណ៍នេសាទឆក់ត្រី និងឧបករណ៍នេសាទស្បៃមុង គ្រប់ប្រភេទ
- ប្រើប្រាស់ឧបករណ៍នេសាទខុសពីការកំណត់នៅក្នុងតារាងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ
- ចិញ្ចឹមត្រី ឬដាំរុក្ខជាតិដែលជាពូជនាំឱ្យខូចដល់បរិស្ថានធម្មជាតិ បំផ្លិចបំផ្លាញដល់ធនធានជលផល ឬបង្កអន្តរាយដល់ដែននេសាទ
- ធ្វើនេសាទ ឬធ្វើអាជីវកម្មផ្សេងៗទៀតដែលប៉ះពាល់ ឬរំខានដល់ ការពងកូន ការលូតលាស់នៃវារីសត្វ ឬវារីរុក្ខជាតិ
- ផលិត ទិញ លក់ ដឹកជញ្ជូន រក្សាទុកឧបករណ៍ឆក់ ឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ ឈិបយន្ត និងអួនអូសទឹកសាប
- ដាំ ឬថែរក្សាដំណាំឈូកក្នុងដែននេសាទ
- ធ្វើនេសាទដោយមង ឬអួនគ្រប់ប្រភេទដែលមានក្រឡាតូចជាង ១.៥ សង្ទីម៉ែត្រ និងធំជាងដប់ប្រាំ(១៥) សង្ទីម៉ែត្រ ក្នុងដែននេសាទទឹកសាប ។

**ប្រការ ៨.–**

ភាគី ខ ត្រូវចាត់វិធានការថែរក្សាការពារកន្លែងនេសាទសហគមន៍ដោយបំផុស ជំរុញ និងលើកទឹកចិត្តដល់សមាជិកសហគមន៍នេសាទគ្រប់រូបឱ្យរាយការណ៍ទៅសមត្ថកិច្ចរដ្ឋបាលជលផលដែលនៅជិតបំផុត ដើម្បីសហការទប់ស្កាត់បទល្មើសជលផល ។

**ប្រការ ៩.–**

ភាគី ខ ត្រូវអនុវត្តនូវភារកិច្ចដូចខាងក្រោម ÷
- ប្រតិបត្តិយ៉ាងម៉ឺងម៉ាត់តាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ធានាឱ្យសមាជិកទាំងអស់ក្នុងសហគមន៍មានសិទ្ធិស្មើគ្នាលើការប្រើប្រាស់ធនធានជលផល
- សហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ និងអាជ្ញាធរដែលពាក់ព័ន្ធ ។

**ប្រការ ១០.–**

ប្រសិនបើភាគី ខ មិនអនុវត្តតាមប្រការទាំងឡាយនៃកិច្ចព្រមព្រៀងនេះ ធ្វើឱ្យអន្តរាយដល់ដែននេសាទ ឬធនធានជលផលត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។

**ប្រការ ១១.–**

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ អាចបញ្ឈប់មុនពេលកំណត់ដោយផ្អែកលើលក្ខខណ្ឌណាមួយ ដូចមានចែងក្នុងមាត្រា ២៧ នៃអនុក្រឹត្យ លេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ។

ក្នុងករណីដែលសហគមន៍នេសាទយល់ថា ការបញ្ឈប់កិច្ចព្រមព្រៀងពុំមានលក្ខណៈសមស្រប សហគមន៍នេសាទអាចធ្វើការតវ៉ាមកប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល ។

**ប្រការ ១២.-**

កិច្ចព្រមព្រៀងនេះអាចធ្វើការកែប្រែបានតាមការឯកភាពរបស់ភាគីទាំង ២ ស្របតាមច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងសហគមន៍នេសាទ ។

កិច្ចព្រមព្រៀងនេះត្រូវតម្កល់ទុកនៅស្នាក់ការសហគមន៍នេសាទ សាលាឃុំ សង្កាត់ ខណ្ឌរដ្ឋបាលជលផល សាលាខេត្ត ក្រុង រដ្ឋបាលជលផលថ្នាក់កណ្តាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយអាចចម្លងជូនស្ថាប័នពាក់ព័ន្ធដោយច្បាប់ចម្លងត្រូវមានប្រថាប់ត្រា ។

ថ្ងៃទី...១១... ខែ ...មករា... ឆ្នាំ ...២០០៧...

**ភាគី ក**

**ជ. នាយខណ្ឌរដ្ឋបាលជលផលពោធិ៍សាត់**

**ប្រធានការិយាល័យជលផលខេត្ត**

ហត្ថលេខា

ប៉ែន_ផាន់រិទ្ធិ

**ភាគី ខ**

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

ហត្ថលេខា

**សាក្សី**

**មេឃុំ** ......................................

ហត្ថលេខា

អ៊ូច_យឿន



ផែនទីកន្លែងនេសាទសហគមន៍ត្រាំពែរ
ឃុំស្នាមព្រះ ស្រុកបាកាន ខេត្តពោធិ៍សាត់
GCP01
GCP02
GCP03
GCP04
GCP05
GCP06
GCP07
GCP08
GCP09
GCP10
បឹងព្រួច
បឹងក្រចាប់
បឹងកក
បឹងខ្យង
បឹងខ្លាច
បឹងប្រស្នឹង
ស្រះរូម
បឹងបាយនៅ
ភូមិត្រាំពែរ
ភូមិបត់ត្រាច
មាត្រដ្ឋាន ១:៥០.០០០
0 ១ ២ គ.ម
ផលិតដោយៈ
ក្រុមផែនទី - គម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប
ផ្នែកទី ២ ( ខេត្តពោធិ៍សាត់)
ខែ តុលា ២០០៦
ប្រភពទិន្នន័យៈ
ព្រំប្រទល់រដ្ឋបាលៈ នាយកដ្ឋានភូមិសាស្ត្រ ២០០៣
ព្រំប្រទល់ឡូត៍នេសាទៈ រដ្ឋបាលជលផល
ព្រំប្រទល់កន្លែងនេសាទសហគមន៍ៈ ប្រមូលព័ត៌មានដោយឧបករណ៍ ជីភីអេស
ផ្លូវ - បឹង - ស្ទឹង - ព្រែកៈ រដ្ឋបាលជលផល២០០៦
ប្រព័ន្ធកូអរដោនេៈ
យូធីអឹម
អេវើរែស ១៨៣០
ឥណ្ឌា ១៩៦០
លេខៈ ៤៨ ខាងជើង
កំណត់សំគាល់ៈ
ទីតាំងភូមិសហគមន៍នេសាទ
ទីតាំងភូមិ
ទីតាំងបង្គោលព្រំប្រទល់
ព្រំប្រទល់ឃុំ
ស្ទឹង - ព្រែក
ផ្លូវ
ព្រំប្រទល់កន្លែងនេសាទសហគមន៍
ព្រំប្រទល់កន្លែងនេសាទសហគមន៍ជិតខាង
ព្រំប្រទល់ឡូតិ៍នេសាទ
បឹង

ត្រាំពែរ. ថ្ងៃទី15 ខែ12 ឆ្នាំ២០០6
ប្រធានគណៈកម្មការសហគមន៍នេសាទត្រាំពែរ

លេខៈ ១០៦/០៦ ៣
បានឃើញ និង បញ្ជូនមក
លោកអភិបាលស្រុកបាកាន
" ដើម្បីពិនិត្យ និង សំរួល "
ស្នាមព្រះ. ថ្ងៃទី15 ខែ12 ឆ្នាំ២០០6
លោកមេឃុំស្នាំព្រះ

ស៊ុច_សឿន

លេខៈ ០១១... ៣
បានឃើញ និង បញ្ជូនមក
លោកប្រធានមន្ទីរកសិកម្ម
" ដើម្បីពិនិត្យ និង សំរួល "
ពោធិ៍សាត់. ថ្ងៃទី១១ ខែ០១ ឆ្នាំ២០០6
ប្រធានការិយាល័យជលផល

ប៉ែន_ផាន់រិទ្ធិ

លេខៈ ...
បានឃើញ .....
កោះជុំ. ថ្ងៃទី15 ខែ12 ឆ្នាំ២០០6
លោកមេឃុំកោះជុំ

ទ៊ាន់_ស៊ុំ

បានឃើញ និង បញ្ជូនមក
លោកមេឃុំស្នាមព្រះ
" ដើម្បីពិនិត្យ និង សំរួល "
ត្រាំពែរ. ថ្ងៃទី15 ខែ12 ឆ្នាំ២០០6
លោកមេភូមិត្រាំពែរ

លេខៈ 14 បក
បានឃើញ និង បញ្ជូនមក
លោកប្រធានការិយាល័យជលផល
" ដើម្បីពិនិត្យ និង សំរួល "
បាកាន. ថ្ងៃទី04 ខែ01 ឆ្នាំ២០០7
អភិបាលស្រុកបាកាន

សុខ_លីមុត

លេខៈ ...
បានឃើញ និង បញ្ជូនមក
ឯកឧត្តមអភិបាលខេត្ត
" ដើម្បីពិនិត្យ និង សំរួល "
ពោធិ៍សាត់. ថ្ងៃទី... ខែ... ឆ្នាំ២០០៧
ប្រធានមន្ទីរកសិកម្ម

ម៉ិច_សំរឿន

លេខៈ ...
បានឃើញ និង ឯកភាព
ពោធិ៍សាត់. ថ្ងៃទី... ខែ... ឆ្នាំ២០០៧
អភិបាលខេត្ត

ឆាយ_សារ៉េត

លេខៈ ៦១៨ កសក
បានឃើញ និងឯកភាព
ភ្នំពេញ ថ្ងៃទី១០ ខែ... ឆ្នាំ២០០៨
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
រដ្ឋលេខាធិការ

លេខៈ ...
បានឃើញ និងគោរពជូន
ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មេត្តាពិនិត្យ និងសម្រេច
ភ្នំពេញ ថ្ងៃទី០៣ ខែ... ឆ្នាំ២០០៨
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល

ណៅ_ធួក

# បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ ត្រាំពែរ
## ភូមិ ត្រាំពែរ ឃុំ ស្អាមព្រះ ស្រុក បាកាន ខេត្តពោធិសាត់

| ល.រ | ឈ្មោះសមាជិក | អាយុ | ភេទ | ភូមិ | ឃុំ | ថ្ងៃ ខែចូលជាសមាជិក |
|---|---|---|---|---|---|---|
| ១ | នួន ង៉ិក | ២០ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១១-០១-២០០៦ |
| ២ | សែត ផាន | ២០ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១១-០១-២០០៦ |
| ៣ | ផង់ នឿន | ៣១ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១១-០១-២០០៦ |
| ៤ | ផាត ធឿន | ២៥ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១១-០១-២០០៦ |
| ៥ | វ៉ាន់ ម៉ក់ | ២៣ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១១-០១-២០០៦ |
| ៦ | ផង់ ច្រិល | ៣៥ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១១-០១-២០០៦ |
| ៧ | អួត រុន | ៤១ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១១-០១-២០០៦ |
| ៨ | និន អ៊ិន | ៣៨ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១១-០១-២០០៦ |
| ៩ | ផន វុត | ២៥ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១១-០១-២០០៦ |
| ១០ | សុង វ៉ាម | ២៣ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១១-០១-២០០៦ |
| ១១ | សុង សុក្រ | ៤២ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១១-០១-២០០៦ |
| ១២ | សួរ យឿន | ៥៤ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១១-០១-២០០៦ |
| ១៣ | ផង់ ក្រាក់ | ៤៦ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១១-០១-២០០៦ |
| ១៤ | ព្រាប ដ៏រ | ៣៩ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១១-០១-២០០៦ |
| ១៥ | នួន ហឿម | ៤៦ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១១-០១-២០០៦ |
| ១៦ | សៀន សឿន | ២៦ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១១-០១-២០០៦ |
| ១៧ | អួត រះ | ៣១ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១១-០១-២០០៦ |
| ១៨ | ហ៊ាន ខេន | ៤៦ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១១-០១-២០០៦ |
| ១៩ | សៀវ សុខឃន | ៤៥ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១១-០១-២០០៦ |
| ២០ | ប៉េះ ឡឹម | ៣៧ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១១-០១-២០០៦ |
| ២១ | អួត ឆក់ | ២៩ | ស្រី | ត្រាំពែរ | ស្អាមព្រះ | ១១-០១-២០០៦ |
| ២២ | ព្រាប យឿន | ៤៨ | ស្រី | ត្រាំពែរ | ស្អាមព្រះ | ១១-០១-២០០៦ |
| ២៣ | ចុង សាមឿន | ៣៩ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១២-០១-២០០៦ |
| ២៤ | អួត រឹម | ២៤ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១២-០១-២០០៦ |
| ២៥ | ព្រាប ទី | ៣៧ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១២-០១-២០០៦ |
| ២៦ | ស្វាយ នីន | ៣៣ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១២-០១-២០០៦ |
| ២៧ | ផង់ លៀង | ២៣ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១២-០១-២០០៦ |
| ២៨ | សុក្រ នឿន | ៤៩ | ស្រី | ត្រាំពែរ | ស្អាមព្រះ | ១៤-០១-២០០៦ |
| ២៩ | អ៊ឹង យឿន | ៦១ | ប្រុស | ត្រាំពែរ | ស្អាមព្រះ | ១៤-០១-២០០៦ |

| ល.រ | ឈ្មោះសមាជិក | អាយុ | ភេទ | ភូមិ | ឃុំ | ថ្ងៃ-ខែចូលជាសមាជិក |
|---|---|---|---|---|---|---|
| ៣០ | សុក្រ ខុំ | ២៦ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៤-០១-២០០៦ |
| ៣១ | គីម គឿន | ២៦ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៤-០១-២០០៦ |
| ៣២ | ច្រឹក សែន | ២៤ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៥-០១-២០០៦ |
| ៣៣ | សុង សេត្យ | ២៥ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៥-០១-២០០៦ |
| ៣៤ | អ៊ុង ម៉ុន | ៦៣ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៥-០១-២០០៦ |
| ៣៥ | ព្រាប សុង | ៧៧ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៥-០១-២០០៦ |
| ៣៦ | សំ ផានិល | ៣៧ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៥-០១-២០០៦ |
| ៣៧ | ដេត អ៊ីន | ៤៥ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៥-០១-២០០៦ |
| ៣៨ | ព្រាប ឆុង | ៤៧ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៦-០១-២០០៦ |
| ៣៩ | ប៊ុត សុខនន | ២១ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៦-០១-២០០៦ |
| ៤០ | សឹម ចាន់ថន | ៣១ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៦-០១-២០០៦ |
| ៤១ | ជួន គ្រោះ | ៣១ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៦-០១-២០០៦ |
| ៤២ | ប៊ុត ផល | ២៣ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៦-០១-២០០៦ |
| ៤៣ | ចុង ញឿន | ៣៧ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៦-០១-២០០៦ |
| ៤៤ | ចោម ជឿម | ៣៩ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៦-០១-២០០៦ |
| ៤៥ | សយ រ៉ុ | ២៩ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៦-០១-២០០៦ |
| ៤៦ | សុក្រ ហៃរ | ៤៧ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៦-០១-២០០៦ |
| ៤៧ | ភីម ហ៊ន | ៣៤ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៦-០១-២០០៦ |
| ៤៨ | អាង ចានឿន | ២៤ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៦-០១-២០០៦ |
| ៤៩ | ជាល សុខនី | ៣៩ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៦-០១-២០០៦ |
| ៥០ | ជា ម៉ៅ | ៣៩ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៦-០១-២០០៦ |
| ៥១ | ទូន ថា | ៣៣ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៦-០១-២០០៦ |
| ៥២ | ព្រាប ជុយ | ៤០ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៦-០១-២០០៦ |
| ៥៣ | ហៀន ឆេង | ៥៦ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ១៦-០១-២០០៦ |
| ៥៤ | យឹង ហាច | ៧១ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ១៦-០១-២០០៦ |
| ៥៥ | ម៉ី ម៉ឺន | ៣៧ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៩-០១-២០០៦ |
| ៥៦ | ឈួន ឈៀង | ៤៨ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២៧-០៦-២០០៦ |
| ៥៧ | ឈិត គ្រិប | ៤៩ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៥៨ | យឹង ធន | ៦១ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៧-០៦-២០០៦ |
| ៥៩ | ហ៊ាន ខេន | ៤៧ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២៧-០៦-២០០៦ |
| ៦០ | សុខ វ៉ាន់ | ៥៥ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៦១ | សយ ផាត | ២៦ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២៧-០៦-២០០៦ |
| ៦២ | ស៊ុន កេន | ២៩ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៧-០៦-២០០៦ |

| ល.រ | ឈ្មោះសមាជិក | អាយុ | ភេទ | ភូមិ | ឃុំ | ថ្ងៃ ខែចូលជាសមាជិក |
|---|---|---|---|---|---|---|
| ៦៣ | សយ ម៉ាច | ២៨ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៦៤ | ស្រី គៀន | ៦៥ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២៧-០៦-២០០៦ |
| ៦៥ | លីម សុខា | ២៤ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៦៦ | ឡឿង ច្រិប | ២៧ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៧-០៦-២០០៦ |
| ៦៧ | វ៉ែន ខន | ៤៥ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៦៨ | យឹង ប៊ិន | ៦៨ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៧-០៦-២០០៦ |
| ៦៩ | ឈួន វ៉េត | ៣១ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៧០ | គុង ស៊ីង | ៦៥ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៧១ | ថាន់ ណន | ៤៦ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២៧-០៦-២០០៦ |
| ៧២ | វ៉ាន់ អ៊ូក | ៣១ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៧៣ | សោម សុខុម | ២៦ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៧-០៦-២០០៦ |
| ៧៤ | អ៊ុក សាវ៉ាន់ | ៦៤ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៧៥ | សោម សុខជា | ២៩ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៧-០៦-២០០៦ |
| ៧៦ | ហែម មាន | ៤៥ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៧-០៦-២០០៦ |
| ៧៧ | កាយ គឿន | ៣៥ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៧៨ | ម៉ៃ ទា | ៥៤ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៧-០៦-២០០៦ |
| ៧៩ | គៀត ចាន់នី | ២៨ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៧-០៦-២០០៦ |
| ៨០ | ឈួន ស៊ាងលី | ២៥ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៨១ | សុខ ហ៊ួន | ៤៩ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៧-០៦-២០០៦ |
| ៨២ | សយ ម៉ៅ | ៣៧ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៨៣ | ទូន សុខខេង | ៤៣ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៨៤ | កើត ខន | ២៧ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៨៥ | កើត ខន | ២៧ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៨៦ | ស៊ុម ឡុងឌី | ៤៤ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៨៧ | ទូន ចាន់នី | ២៧ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៨៨ | សន្ធ ឆន | ៤២ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៨៩ | ទូន គីមសេង | ៤៦ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៩០ | ភីម ច្រិប | ២៣ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៩១ | ស៊ិន សុម៉ាលី | ២៩ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៩២ | កាយ ភី | ២៨ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៩៣ | ថាប់ ភឿន | ៥៥ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១២-០៧-២០០៦ |
| ៩៤ | សេង ធា | ២៥ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៩៥ | ផល ខុម | ៣៨ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |

| ល.រ | ឈ្មោះសមាជិក | អាយុ | ភេទ | ភូមិ | ឃុំ | ថ្ងៃ-ខែចូលជាសមាជិក |
|---|---|---|---|---|---|---|
| ៩៦ | ទូន ខុម | ៣៥ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៩៧ | កុង សុភាព | ២៦ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៩៨ | ស៊ូង គី | ៣៨ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ៩៩ | ជឹម គឹមលាង | ៤០ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ១០០ | អ៊ូន អាន់ | ៥១ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ១០១ | កាយ ផារី | ២៥ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ១០២ | ធាម ម៉ៅ | ២៣ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ១០៣ | មឹម មាន់ | ២៥ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ១០៤ | សុខ មឹម | ៤៦ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ១០៥ | សុខ រិន | ៥៦ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ១០៦ | ផល ផាន់ | ៥៣ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ១០៧ | ទូន ខា | ៣០ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២៦-០៦-២០០៦ |
| ១០៨ | លន ធី | ២២ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១២-០៧-២០០៦ |
| ១០៩ | គារ ប៊ុម | ៣៤ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១២-០៧-២០០៦ |
| ១១០ | សន ប៊ុន | ៤៥ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១២-០៧-២០០៦ |
| ១១១ | គីង ចុត | ៧១ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៤-០៧-២០០៦ |
| ១១២ | យឹម វឿន | ៤៦ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១២-០៧-២០០៦ |
| ១១៣ | ហួន ភារ | ៣៦ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៤-០៧-២០០៦ |
| ១១៤ | សយ ផា | ៣៨ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៤-០៧-២០០៦ |
| ១១៥ | នូវ គឿង | ៣៩ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៤-០៧-២០០៦ |
| ១១៦ | អូត ពន | ៤៥ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៤-០៧-២០០៦ |
| ១១៧ | សែម យ៉ិ | ៤៩ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៤-០៧-២០០៦ |
| ១១៨ | សន ប៉ាល់ | ៥៥ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៤-០៧-២០០៦ |
| ១១៩ | អ៊ឹង យឿម | ៤៥ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៤-០៧-២០០៦ |
| ១២០ | គង់ ថេត | ៤១ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៤-០៧-២០០៦ |
| ១២១ |ញឹក តក | ៥៦ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២៧-០៦-២០០៦ |
| ១២២ | ឆែម យៀមលី | ២៧ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៤-០៧-២០០៦ |
| ១២៣ | ចាន់ អៀម | ៣៨ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៤-០៧-២០០៦ |
| ១២៤ | កើត សារិន | ៥១ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៤-០៧-២០០៦ |
| ១២៥ | ឡាំ ស៊ីថារ | ៤២ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៤-០៧-២០០៦ |
| ១២៦ | នូវ ជុំ | ៤៥ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៤-០៧-២០០៦ |
| ១២៧ | គង់ ធុយ | ៣៨ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៤-០៧-២០០៦ |
| ១២៨ | ញឹក ហៀង | ៣៥ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ១៤-០៧-២០០៦ |

| ល.រ | ឈ្មោះសមាជិក | អាយុ | ភេទ | ភូមិ | ឃុំ | ថ្ងៃ ខែចូលជាសមាជិក |
|---|---|---|---|---|---|---|
| ១២៩ | គា ជីម | ៦២ | ប្រុស | ត្រាំពែរ | ស្ពានព្រះ | ១២-០១-២០០៦ |
| ១៣០ | ប៉ាត សុត | ៤៨ | ប្រុស | ត្រាំពែរ | ស្ពានព្រះ | ១៤-០១-២០០៦ |
| ១៣១ | សែត ផាន | ២២ | ប្រុស | ត្រាំពែរ | ស្ពានព្រះ | ២៧-០៦-២០០៦ |
| ១៣២ | គៀត ចាន់ណា | ២៦ | ប្រុស | ត្រាំពែរ | ស្ពានព្រះ | ២៧-០៦-២០០៦ |
| ១៣៣ | ជា ធីម | ៤១ | ស្រី | ត្រាំពែរ | ស្ពានព្រះ | ២៧-០៦-២០០៦ |
| ១៣៤ | គារ សៀប | ៣៤ | ប្រុស | ត្រាំពែរ | ស្ពានព្រះ | ១២-០១-២០០៦ |
| ១៣៥ | ឈួន គានី | ៣៥ | ស្រី | ត្រាំពែរ | ស្ពានព្រះ | ២៦-០៦-២០០៦ |
| ១៣៦ | គិន អួន | ៤៥ | ស្រី | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |
| ១៣៧ | ម៉ន ឌីម៉ាន់ | ១៩ | ស្រី | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |
| ១៣៨ | ម៉ន យាយ | ១៨ | ស្រី | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |
| ១៣៩ | ឈន ឈី | ២១ | ប្រុស | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |
| ១៤០ | ម៉ឹម ហ៊ីង | ២៣ | ស្រី | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |
| ១៤១ | យាយ មន់ | ៧៣ | ស្រី | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |
| ១៤២ | ចាន់ ស៊ន | ៦២ | ស្រី | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |
| ១៤៣ | គង់ ស៊ីង | ៦៥ | ប្រុស | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |
| ១៤៤ | ភីម សុន | ២២ | ប្រុស | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |
| ១៤៥ | ភីម សាក់ | ១៨ | ស្រី | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |
| ១៤៦ | ឈួន រ៉េន | ៣២ | ស្រី | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |
| ១៤៧ | ឈួន លាង | ២១ | ប្រុស | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |
| ១៤៨ | ឈួន លន | ១៩ | ប្រុស | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |
| ១៤៩ | ជាល ទិត្យ | ២៥ | ប្រុស | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |
| ១៥០ | ឈួន រ៉ែម | ២៤ | ស្រី | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |
| ១៥១ | ឈួន គានី | ៤២ | ប្រុស | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |
| ១៥២ | ចាន់ ណុល | ៣៨ | ស្រី | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |
| ១៥៣ | ជឿន វីត | ២៥ | ប្រុស | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |
| ១៥៤ | សោម សុខុម | ២០ | ស្រី | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |
| ១៥៥ | សោម សឿន | ៧៤ | ប្រុស | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |
| ១៥៦ | សោម រឿម | ២៤ | ប្រុស | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |
| ១៥៧ | សោម សុខគី | ២១ | ស្រី | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |
| ១៥៨ | ជួន ឌឿន | ៥៣ | ស្រី | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |
| ១៥៩ | ស្រី សំបូមាស់ | ២២ | ស្រី | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |
| ១៦០ | ជាល ឈន | ៧២ | ប្រុស | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |
| ១៦១ | សោម ឈុំ | ១៨ | ប្រុស | ត្រាំពែរ | ស្ពានព្រះ | ២០-១២-២០០៦ |

| ល.រ | ឈ្មោះសមាជិក | អាយុ | ភេទ | ភូមិ | ឃុំ | ថ្ងៃ ខែចូលជាសមាជិក |
|---|---|---|---|---|---|---|
| ១៦២ | សួយ អ៊ិន | ៤០ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៦៣ | អួត ចាន់ហៀង | ៤០ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៦៤ | នាត | ១៩ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៦៥ | មឹក | ៧០ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៦៦ | ចុង ស៊ីន | ៣៩ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៦៧ | អួត ជីប | ៣០ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៦៨ | សុង វាំ | ២០ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៦៩ | អ៊ិន មុំ | ២១ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៧០ | ច្រិក សែន | ២០ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៧១ | វ៉ាត ឈឿត | ២៩ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៧២ | ស្រី ឈាក | ៧០ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៧៣ | សុង នី | ២៣ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៧៤ | សុង ស៊េត | ២៦ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៧៥ | ជា ភា | ៣០ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៧៦ | គីម គីម | ៥០ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៧៧ | ង៉ែត សុផល | ៤៧ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៧៨ | គីម គឿន | ២៨ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៧៩ | គីម ស៊ីនឿន | ២៥ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៨០ | គីម វ៉ាន្នូ | ២៣ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៨១ | គីម វ៉ាន់ណា | ១៩ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៨២ | តាត ចាន់ទ្ធី | ២៤ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៨៣ | ចាន់ នឿន | ២៦ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៨៤ | តាត ហៀក | ៤១ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៨៥ | យ៉ឹង ហ៊ន | ៥០ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៨៦ | តាត ហ៊ត | ១៩ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៨៧ | កង គន | ២៣ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៨៨ | នូ ភារុម | ៣៨ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៨៩ | គៀត យុទ្ធី | ៣៨ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៩០ | ឃិន យុង | ៤៩ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៩១ | សុង ណុន | ២៣ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៩២ | សុង ខ្មៅ | ១៨ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៩៣ | សុង រឿម | ១៨ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៩៤ | សុង រីម | ២០ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |

| ល.រ | ឈ្មោះសមាជិក | អាយុ | ភេទ | ភូមិ | ឃុំ | ថ្ងៃ ខែចូលជាសមាជិក |
|---|---|---|---|---|---|---|
| ១៩៥ | ចុង សារ៉េ | ៤៨ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៩៦ | សូ យឿន | ៥៦ | ប្រុស | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៩៧ | ចាន់ សឿន | ៥៦ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |
| ១៩៨ | ចាន់ ស៊ក | ៣១ | ស្រី | ត្រាំពែរ | ស្នាមព្រះ | ២០-១២-២០០៦ |

សមាជិកសរុបចំនួន ១៩៨ នាក់ ក្នុងនោះមាន :

- ប្រុសចំនួន : ១២៣ នាក់
- ស្រី ចំនួន : ៧៥ នាក់

ថ្ងៃទី 31 ខែ 12 ឆ្នាំ២០០៦

**ប្រធានសហគមន៍នេសាទត្រាំពែរ**

បានឃើញនិងឯកភាព

ថ្ងៃទី 31 ខែ 12 ឆ្នាំ២០០៦

**មេភូមិត្រាំពែរ**

បានឃើញនិងឯកភាព

ថ្ងៃទី 31 ខែ 12 ឆ្នាំ២០០៦

**មេឃុំស្នាមព្រះ**

រឿប_យឿន

# បញ្ជីឈ្មោះគណៈកម្មការសហគមន៍នេសាទត្រាំពែរ

ឃុំស្នាមព្រះ   ស្រុកបាកាន   ខេត្តពោធិ៍សាត់

| ល.រ | ឈ្មោះ | ភេទ | អាយុ | ភូមិ | តួនាទីក្នុងគណៈកម្មការ |
|---|---|---|---|---|---|
| ១ | ទូន ផាង | ប្រុស | ៣៩ | ត្រាំពែរ | ប្រធាន |
| ២ | ប៉េះ ឡឹម | ប្រុស | ៣៩ | ត្រាំពែរ | អនុប្រធាន |
| ៣ | អាង សៅនី | ស្រី | ២០ | ត្រាំពែរ | លេខា |
| ៤ | ម៉ន ឌីម៉ាន់ | ស្រី | ២១ | ត្រាំពែរ | បេឡា |
| ៥ | ព្រាប ឈឿន | ស្រី | ៥០ | ត្រាំពែរ | ផ្សព្វផ្សាយ |
| ៦ | សុខ រិន | ស្រី | ៦៦ | ត្រាំពែរ | ផ្សព្វផ្សាយ |
| ៧ | ឡុក ហួរ | ប្រុស | ៣៩ | ត្រាំពែរ | ប្រធានល្បាត |
| ៨ | សន ប៊ុន | ប្រុស | ៤៧ | ត្រាំពែរ | ល្បាត |
| ៩ | ឈួន គានី | ប្រុស | ៤៣ | ត្រាំពែរ | ល្បាត |
| ១០ | ហ៊ួ ឡៃហ៊ី | ប្រុស | ២៥ | ត្រាំពែរ | ល្បាត |
| ១១ | ចោម ជឿម | ប្រុស | ៣៥ | ត្រាំពែរ | ល្បាត |

ធ្វើនៅ...ស្នាមព្រះ...ថ្ងៃទី...18...ខែ...02...ឆ្នាំ២០០៨

**ប្រធានគណៈកម្មការសហគមន៍នេសាទត្រាំពែរ**

ទូន ផាង

បានឃើញ និង បញ្ជាក់ថា

ឈ្មោះនៅក្នុងបញ្ជីខាងលើនេះ

គឺជាសមាជិកគណៈកម្មការសហគមន៍នេសាទត្រាំពែរ

ពិតប្រាកដមែន ។

ស្នាមព្រះ...ថ្ងៃទី...18...ខែ...02...ឆ្នាំ២០០៨

**មេឃុំស្នាមព្រះ**

អ៊ុច_ឈឿន

ឧបសម្ព័ន្ធ ១

## រចនាសម្ព័ន្ធគណៈកម្មការសហគមន៍នេសាទ ត្រាំពែរ

Tram Peaer Community Fisheries Committee Structure




**កំនត់សំគាល់**

........ ទីប្រឹក្សា

══════ អ្នកគាំទ្រ

────── គ្រប់គ្រង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លក្ខន្តិកៈសហគមន៍នេសាទ ត្រាំពែរ

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | : | ត្រាំពែរ |
| ភូមិ | : | ត្រាំពែរ |
| ឃុំ | : | ស្នាមព្រះ |
| ស្រុក | : | បាកាន |
| ខេត្ត | : | ពោធិ៍សាត់ |

## ជំពូកទី ១
## គោលបំណង និងនាមករណ៍

**ប្រការ ១.-**

លក្ខន្តិកៈនេះមានគោលបំណង ÷

- កំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការការពារ ការអភិរក្ស ការអភិវឌ្ឍន៍ និងការប្រើប្រាស់ធនធានជលផលរបស់សហគមន៍នេសាទប្រកបដោយនិរន្តរភាព
- ធ្វើជាគោលការណ៍គ្រឹះ និងជាយន្តការសម្រាប់ដំណើរការសហគមន៍នេសាទ
- ការពារសិទ្ធិ និងផលប្រយោជន៍របស់សមាជិកសហគមន៍នេសាទ និងផលប្រយោជន៍សាធារណៈ។

**ប្រការ ២ .-**

ឈ្មោះសហគមន៍នេសាទ ត្រាំពែរ ហៅកាត់ថា ស. ន. ត. ៣ អាសយដ្ឋាន ភូមិ ត្រាំពែរ ឃុំ ស្នាមព្រះ ស្រុក បាកាន ខេត្ត ពោធិ៍សាត់។

សហគមន៍នេសាទនេះមានការចូលរួមពីប្រជាពលរដ្ឋដែលរស់ក្នុង ÷

១. ភូមិ ត្រាំពែរ ឃុំ ស្នាមព្រះ ស្រុក បាកាន

មានកម្មវត្ថុ ដើម្បីបង្កើតជីវភាពប្រជាពលរដ្ឋ តាមរយៈការគ្រប់គ្រងប្រើប្រាស់ អភិរក្ស អភិវឌ្ឍន៍ ធនធានជលផលអោយបានយូរអង្វែង។

## ជំពូកទី ២
## លក្ខខណ្ឌនៃការសុំចូលជាសមាជិក ភារកិច្ច និងសិទ្ធិរបស់សមាជិក

**ប្រការ ៣.-**

ប្រជាពលរដ្ឋទាំងពីរភេទដែលមានបំណងចង់ចូលជាសមាជិកសហគមន៍នេសាទ មានសិទ្ធិដាក់ពាក្យសុំចូលដោយស្ម័គ្រចិត្ត និងត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ÷

- មានលំនៅដ្ឋាននៅក្នុងបណ្តាភូមិនៃសហគមន៍នេសាទ
- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ ឆ្នាំឡើង។

**ប្រការ ៤.-**

សមាជិកសហគមន៍នេសាទដែលបានបំពេញលក្ខខណ្ឌក្នុងប្រការ ៣ ខាងលើមានសិទ្ធិ ÷

- ចូលរួមប្រជុំមហាសន្និបាត និងបោះឆ្នោតស្មើភាពគ្នា

- បោះឆ្នោត និងឈរឈ្មោះជាបេក្ខជននៃគណៈកម្មការសហគមន៍នេសាទស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ
- ទទួលព័ត៌មានអំពីស្ថានភាពសេដ្ឋកិច្ច សង្គមរបស់សហគមន៍នេសាទពីគណៈកម្មការសហគមន៍នេសាទ
- ស្នើឱ្យមានការកោះប្រជុំមហាសន្និបាតវិសាមញ្ញ ដើម្បីធ្វើការពិភាក្សា និងសម្រេចលើបញ្ហាណាមួយ បើមានការស្នើសុំពីសមាជិកយ៉ាងតិចមួយភាគបី (១/៣) នៃសមាជិកសហគមន៍នេសាទទាំងអស់
- ធ្វើនេសាទជាលក្ខណៈគ្រួសារស្របតាមច្បាប់ស្តីពីជលផល កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធវិស័យជលផល
- ចូលរួមក្នុងសកម្មភាពទាំងអស់របស់សហគមន៍នេសាទ
- ប្តឹងតវ៉ា ឬផ្តល់ព័ត៌មានអំពីបាតុភាពទាំងឡាយ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សហគមន៍ទៅសមត្ថកិច្ចរដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធ
- ទទួលការគាំទ្រពីមជ្ឈដ្ឋាននានាដើម្បីផលប្រយោជន៍របស់សហគមន៍។

សមាជិកសហគមន៍នេសាទត្រូវទទួលខុសត្រូវរាល់សកម្មភាពរៀងៗខ្លួន និងរួមគ្នាចំពោះកំហុសដែលខ្លួនបានប្រព្រឹត្តក្នុងពេលបំពេញភារកិច្ចដោយមិនទាន់គិតដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ។

សមាជិកសហគមន៍នេសាទចំនួនមួយភាគដប់(១/១០) ឡើងទៅអាចស្នើសុំឱ្យប្រធានគណៈកម្មការសហគមន៍នេសាទបញ្ចូលបញ្ហាមួយចំនួនទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទសាមី ហើយចំនួនសមាជិកសហគមន៍នេសាទដែលបានស្នើសុំខាងលើនេះអាចចាត់តំណាងចំនួនបី (៣) នាក់ ចូលរួមប្រជុំដើម្បីចោទសួរគណៈកម្មការសហគមន៍នេសាទនូវបញ្ហាទាំងឡាយណាដែលទាក់ទងនឹងចំណុចដែលបានស្នើឡើងនោះ។

## **ប្រការ ៥.–**

សមាជិកសហគមន៍នេសាទមានកាតព្វកិច្ច និងភារកិច្ចដូចខាងក្រោម ÷

- អនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីជលផល
- អនុវត្តតាមព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- អនុវត្តតាមអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ និងលិខិតបទដ្ឋានផ្សេងៗទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ
- អនុវត្តតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- អនុវត្តតាមសេចក្តីសម្រេចរបស់មហាសន្និបាត និងគណៈកម្មការសហគមន៍នេសាទ
- បង់ប្រាក់សមាជិកភាពចំនួន ៣០០ រៀល តាមការសម្រេចរបស់មហាសន្និបាត នៅពេលដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ

- បង់ប្រាក់ភាគទានប្រចាំឆ្នាំចំនួន ៣.០០០ រៀល (បង់ពីរលើកក្នុងមួយឆ្នាំ) តាមការសម្រេចរបស់មហាសន្និបាត
- ចូលរួមក្នុងសកម្មភាពរបស់សហគមន៍នេសាទដើម្បីផលប្រយោជន៍ និងការរីកចំរើនរបស់សហគមន៍ នេសាទ
- ចូលរួមការពារ ថែរក្សា និងគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទ
- ចូលរួមឃ្លាំមើល ទប់ស្កាត់ និងរាយការណ៍រាល់សកម្មភាពបទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍។

## ជំពូកទី ៣
## លក្ខណៈវិនិច្ឆ័យ លក្ខខណ្ឌនៃការលាឈប់ និងការបណ្តេញចេញពីសមាជិក

### ប្រការ ៦._

សមាជិកសហគមន៍នេសាទ មានសិទ្ធិលាឈប់ពីសមាជិកភាពបានដោយ ៖

- ដាក់ពាក្យសុំលាលែងជាលាយលក្ខណ៍អក្សរ
- ការផ្លាស់ប្តូរទីលំនៅចេញពីកន្លែងនេសាទសហគមន៍
- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច ។

### ប្រការ ៧._

សមាជិកសហគមន៍អាចត្រូវបណ្តេញចេញពីសមាជិកភាពក្នុងលក្ខខណ្ឌដូចខាងក្រោម ៖

- ការមិនបង់ភាគទានចំនួន ៣ លើកជាប់ៗគ្នា
- ការធ្វើឱ្យប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍នៃសហគមន៍នេសាទ ឬសមាជិកសហគមន៍នេសាទដទៃទៀត
- សាមីខ្លួនត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម
- សាមីខ្លួនបានប្រព្រឹត្តផ្ទុយនឹងលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ។

## ជំពូកទី ៤
## របៀបរបបកាន់បញ្ជី និង ឯកសារនានា

### ប្រការ ៨._

ប្រភពហិរញ្ញវត្ថុរបស់សហគមន៍នេសាទបានមកពី ៖

- ភាគទានរបស់សមាជិកសហគមន៍នេសាទ
- អំណោយពីសប្បុរសជន
- ជំនួយពីរាជរដ្ឋាភិបាល អង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល

- ចំណូលស្របច្បាប់ផ្សេងៗទៀត។

**ប្រការ ៩.–**

រាល់ការចំណាយថវិកា សហគមន៍ត្រូវអនុវត្តដូចតទៅ ÷

- ការចំណាយពី ១០០ រៀល ដល់ ៣០.០០០ រៀល ត្រូវសម្រេចដោយប្រធានគណៈកម្មការសហគមន៍នេសាទ
- ការចំណាយពី ៣០.១០០ រៀល ដល់ ១០០.០០០ រៀល ត្រូវសម្រេចដោយគណៈកម្មការសហគមន៍នេសាទ
- ការចំណាយពី ១០០.១០០ រៀល ឡើងទៅត្រូវសម្រេចដោយមហាសន្និបាត។

**ប្រការ ១០.–**

សហគមន៍នេសាទត្រូវតម្កល់ទុកឯកសារ និងរៀបចំឱ្យមានបញ្ជី ÷

- ចំណូល ចំណាយថវិកា
- សារពើភណ្ឌ
- សមាជិកសហគមន៍នេសាទ
- កំណត់ហេតុប្រជុំមហាសន្និបាតសហគមន៍នេសាទ
- កំណត់ហេតុប្រជុំគណៈកម្មការសហគមន៍នេសាទ
- ឯកសារដទៃទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ។

**ប្រការ ១១.–**

ការគ្រប់គ្រង និងប្រើប្រាស់ថវិកា ÷

- ការគ្រប់គ្រងថវិកា ត្រូវមានការកាន់បញ្ជីគណនេយ្យ
- ថវិកាចំណូលដែលទទួលបានពីប្រភពផ្សេងៗ ត្រូវរក្សាទុកក្នុងបេឡាររបស់សហគមន៍នេសាទ
- រាល់ថវិកាចំណាយ ត្រូវមានរបាយការណ៍ទូទាត់ដោយមានសក្ខីបត្រ និងចុះបញ្ជីឱ្យបានត្រឹមត្រូវ
- ថវិកាដែលត្រូវចំណាយ គឺសម្រាប់តែបម្រើឱ្យការងារគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍសហគមន៍នេសាទ។

## ជំពូកទី ៥
## គណៈកម្មការសហគមន៍នេសាទ

**ប្រការ ១២.–**

សមាសភាពគណៈកម្មការសហគមន៍នេសាទរួមមាន ប្រធាន អនុប្រធាន និងសមាជិក។ គណៈកម្មការសហគមន៍នេសាទត្រូវបោះឆ្នោតជ្រើសរើសសមាជិកទទួលបន្ទុកលេខាធិការមួយរូប និងសមាជិកទទួលបន្ទុកហិរញ្ញិកមួយរូប និងត្រូវពិភាក្សាបែងចែកភារកិច្ចសមាជិកផ្សេងទៀតតាមការជាក់ស្តែង។

ប្រធានគណៈកម្មការសហគមន៍នេសាទទទួលខុសត្រូវដឹកនាំ និងគ្រប់គ្រងសហគមន៍នេសាទទាំងមូល។ អនុប្រធានគណៈកម្មការសហគមន៍នេសាទជាជំនួយការឱ្យប្រធាន។

**ប្រការ ១៣.-**

គណៈកម្មការសហគមន៍នេសាទមានអាណត្តិប្រាំ (៥)ឆ្នាំ ចាប់ពីថ្ងៃបោះឆ្នោត ហើយផុតកំណត់នៅពេលដែលមានគណៈកម្មការសហគមន៍នេសាទថ្មីដែលត្រូវបានបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាតឱ្យចូលកាន់តំណែងជំនួស។ ក្នុងករណីដែលសហគមន៍នេសាទដំណើរការមិនប្រក្រតី ដោយមូលហេតុដំណើរការមិនល្អ ឬអសមត្ថភាពក្នុងការគ្រប់គ្រងសហគមន៍នេសាទ សមាជិកសហគមន៍នេសាទចំនួនមួយភាគបី (១/៣) មានសិទ្ធិស្នើសុំបើកមហាសន្និបាតវិសាមញ្ញដើម្បីបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទជាថ្មី។

**ប្រការ ១៤.-**

ក្នុងករណីដែលសមាជិកគណៈកម្មការសហគមន៍នេសាទណាម្នាក់អវត្តមាន ដោយគ្មានមូលហេតុរយៈពេលប្រាំមួយ (៦)ខែ ឬសុំលាលែងមុនចប់អាណត្តិ បេក្ខជនដែលមានឈ្មោះតាមសម្លេងគាំទ្របន្ទាប់ក្នុងពេលបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាតកន្លងមក ត្រូវបានជ្រើសតាំងជំនួស។

## ជំពូកទី ៦
## របៀបរបបប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ

**ប្រការ ១៥.-**

គណៈកម្មការសហគមន៍នេសាទត្រូវកំណត់របបប្រជុំឱ្យបានទៀងទាត់រៀងរាល់ខែ។ កិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទអាចប្រព្រឹត្តទៅបាន លុះត្រាតែមានសមាជិកគណៈកម្មការចូលរួមយ៉ាងតិចចំនួន ២/៣ (ពីរភាគបី) នៃសមាសជិករបស់គណៈកម្មការសហគមន៍នេសាទទាំងមូល។

**ប្រការ ១៦.-**

ប្រធានគណៈកម្មការសហគមន៍នេសាទជាអ្នកកោះអញ្ជើញ និងធ្វើជាប្រធានគ្រប់កិច្ចប្រជុំ។ ក្នុងករណីប្រធានគណៈកម្មការសហគមន៍នេសាទអវត្តមាន អនុប្រធានដែលត្រូវបានប្រគល់សិទ្ធិត្រូវធ្វើជាប្រធានអង្គប្រជុំ។ រាល់ការប្រជុំត្រូវមានកំណត់ហេតុ និងបញ្ជីវត្តមានច្បាស់លាស់។

ប្រធានអង្គប្រជុំត្រូវធានាឱ្យគ្រប់កិច្ចប្រជុំសហគមន៍នេសាទប្រព្រឹត្តទៅដោយលក្ខណៈប្រជាធិបតេយ្យ មានរបៀបរៀបរយ និងគ្មានការរំខាន។

ប្រធានអង្គប្រជុំ អាចបណ្តេញសមាជិកអង្គប្រជុំណាម្នាក់ចេញពីកិច្ចប្រជុំបាន ក្នុងករណីដែលសមាជិកនោះធ្វើឱ្យខូចសណ្តាប់ធ្នាប់អង្គប្រជុំ។

**ប្រការ ១៧ .-**

ការសម្រេចលើបញ្ហាណាមួយរបស់សហគមន៍ដូចមានចែងខាងក្រោមនេះ គឺត្រូវអនុម័តដោយកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ ដោយមានសម្លេងគាំទ្រយ៉ាងតិចលើសពីពាក់ កណ្តាលនៃចំនួនសមាជិកគណៈកម្មការ

សហគមន៍នេសាទដែលមានវត្តមានក្នុងអង្គប្រជុំ។ ក្នុងករណីដែលមានសំលេងស្មើគ្នា មតិប្រធានអង្គប្រជុំជាឧត្តមានុភាព ៖

- សេចក្តីព្រាងកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- សេចក្តីព្រាងគម្រោងថវិកា ចំណូល និងចំណាយក្នុងសហគមន៍នេសាទ
- ការឰ្យសមាជិកភាពរបស់សមាជិកដែលមានកំហុស
- ការទទួលពាក្យសុំចូលជាសមាជិកថ្មី
- ការដាក់ទណ្ឌកម្មតាមបទបញ្ជាផ្ទៃក្នុង ដល់សមាជិកសហគមន៍នេសាទ។

បន្ទាប់ពីកិច្ចប្រជុំចប់ភ្លាម ប្រធានគណៈកម្មការសហគមន៍នេសាទត្រូវចាត់ឱ្យធ្វើការជូនដំណឹងដល់សមាជិកសហគមន៍នេសាទអំពីសេចក្តីសម្រេចរបស់ខ្លួន។ សេចក្តីសម្រេចនៃអង្គប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការសហគមន៍នេសាទ ឬសាលាឃុំ ក្នុងរយៈពេល ៧ ថ្ងៃយ៉ាងយូរបន្ទាប់ពីការប្រជុំ។

## ជំពូកទី ៧
## មហាសន្និបាតសហគមន៍នេសាទ

**ប្រការ ១៨.–**

មហាសន្និបាតសហគមន៍នេសាទជាអង្គប្រជុំកំពូល ដើម្បីធ្វើការអនុម័ត និងធ្វើសេចក្តីសម្រេចទាំងឡាយក្នុងនាមសហគមន៍នេសាទ។ មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទត្រូវប្រារព្ធធ្វើឡើង បន្ទាប់ពីក្រុមស្ថាបនិកបានរៀបចំរួចរាល់នូវកិច្ចការទាំងឡាយដែលពាក់ព័ន្ធនឹងដំណើរការមហាសន្និបាត។

ការកោះប្រជុំមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ ធ្វើឡើងដោយក្រុមប្រឹក្សាឃុំ ដោយមានការជួយសម្របសម្រួលពីសមត្ថកិច្ចរដ្ឋបាលជលផល តាមការស្នើសុំរបស់ក្រុមស្ថាបនិក ហើយត្រូវមានការចូលរួមពីសមាជិកដែលបានដាក់ពាក្យស្នើសុំរួចមកហើយ។

មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ អនុម័តនូវសេចក្តីសម្រេច និងកិច្ចការសំខាន់ដូចខាងក្រោម ៖

- អ្នកដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ
- ឈ្មោះសហគមន៍នេសាទ
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ។

**ប្រការ ១៩.–**

មហាសន្និបាតសាមញ្ញត្រូវរៀបចំឡើង ១ ឆ្នាំម្តង ដើម្បីសរុបលទ្ធផលការងារប្រចាំឆ្នាំ និងអនុម័តនូវកិច្ចការសំខាន់ៗរបស់សហគមន៍នេសាទ។ ក្នុងករណីចាំបាច់ សហគមន៍អាចរៀបចំមហាសន្និបាតវិសាមញ្ញតាមការស្នើសុំពីសមាជិកសហគមន៍នេសាទចំនួនមួយភាគបី (១/៣) យ៉ាងតិច។

## ប្រការ ២០.–

គណៈកម្មការសហគមន៍នេសាទអាចអញ្ជើញរដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ សមត្ថកិច្ច ពាក់ព័ន្ធ និងអ្នកគាំទ្រចូលរួមសង្កេតការណ៍ ឬសម្របសម្រួល ឬជាកិត្តិយសក្នុងមហាសន្និបាតសហគមន៍នេសាទ។

## ប្រការ ២១.–

លក្ខខណ្ឌនៃដំណើរការមហាសន្និបាតមានដូចខាងក្រោម ÷

- ត្រូវធ្វើការផ្សព្វផ្សាយសេចក្ដីជូនដំណឹងជាសាធារណៈ និងបិទប្រកាសនៅសាលាឃុំ និងទីស្នាក់ការសហគមន៍នេសាទ
- ការកោះអញ្ជើញសមាជិកសហគមន៍នេសាទឱ្យចូលរួមមហាសន្និបាតសាមញ្ញត្រូវធ្វើឡើងដប់ (១០) ថ្ងៃយ៉ាងតិច មុនថ្ងៃបើកមហាសន្និបាត និងបី (៣) ថ្ងៃយ៉ាងតិចមុនថ្ងៃមហាសន្និបាតវិសាមញ្ញ
- មហាសន្និបាតសាមញ្ញ ឬវិសាមញ្ញអាចប្រជុំពិភាក្សាអនុម័ត និងសម្រេចបានលុះត្រាតែមានវត្តមានលើសពីពាក់កណ្ដាលនៃចំនួនសមាជិកសហគមន៍នេសាទ
- អង្គប្រជុំមហាសន្និបាតដឹកនាំដោយប្រធានគណៈកម្មការសហគមន៍នេសាទ ឬប្រធានអង្គប្រជុំដែលជ្រើសរើសដោយការអនុម័តក្នុងចំណោមសមាជិកវត្តមាន
- មហាសន្និបាតត្រូវអនុម័តលេខាកត់ត្រា ដើម្បីធ្វើកំណត់ហេតុ សេចក្ដីសម្រេច និងបញ្ជីវត្តមាន
- លេខាកត់ត្រា និងប្រធានអង្គប្រជុំត្រូវចុះហត្ថលេខាលើកំណត់ហេតុ
- សមាជិកម្នាក់មានសំឡេងតែមួយគត់ ហើយមិនអាចបញ្ជូនមនុស្សមកតំណាងបានទេ
- សេចក្ដីសម្រេចរបស់មហាសន្និបាត ត្រូវយកសំឡេងលើសពីពាក់កណ្ដាលនៃចំនួនសមាជិកដែលមានវត្តមាន។

## ប្រការ ២២.–

មហាសន្និបាតអនុម័ត ÷

- សេចក្ដីសម្រេចដូចមានចែងក្នុងប្រការ ១៨ កថាខណ្ឌទី ៣ នៃលក្ខន្តិកៈនេះ
- កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
- ការសុំលាលែង ឬការបណ្ដេញចេញពីសមាជិកភាព ឬពីសមាជិកគណៈកម្មការសហគមន៍នេសាទ
- របាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មការសហគមន៍នេសាទ
- គម្រោងចំណូល ចំណាយរបស់សហគមន៍នេសាទ។

## ជំពូកទី ៨
## ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ

**ប្រការ ២៣.-**

ចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទ និងចំនួនបេក្ខជនឈរឈ្មោះត្រូវអនុម័តដោយមហាសន្និបាត ។

**ប្រការ ២៤.-**

កិច្ចដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទគឺជាភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតដែលអនុម័តដោយមហាសន្និបាត ។ គណៈកម្មការរៀបចំការបោះឆ្នោតមានសមាសភាពពីបី (៣) ទៅប្រាំ(៥)នាក់ ដែលមានប្រធាន អនុប្រធាន និងសមាជិក តាមការកំណត់ជាក់ស្តែងរបស់មហាសន្និបាត និងត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានចំណេះដឹង និងមានសីលធម៌ល្អ ។ គណៈកម្មការរៀបចំការបោះឆ្នោតត្រូវធ្វើការប្តេជ្ញាចិត្តបង្ហាញពីភាពស្មោះត្រង់ ។

**ប្រការ ២៥.-**

គណៈកម្មការរៀបចំការបោះឆ្នោតមានភារកិច្ចដូចខាងក្រោម ÷

- ប្រកាសបេក្ខជនឈរឈ្មោះ
- ណែនាំអំពីនីតិវិធីនៃការបោះឆ្នោត
- បង្ហាញរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
- រាប់សន្លឹកឆ្នោត និងសរុបលទ្ធផលជូនគណៈអធិបតីដើម្បីប្រកាសជូនមហាសន្និបាត
- ភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ បន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតចប់ជាស្ថាពរ ។

**ប្រការ ២៦.-**

បេក្ខជនដែលទទួលបានសំឡេងឆ្នោតគាំទ្រច្រើនជាងគេបង្អស់ គឺជាប្រធានគណៈកម្មការសហគមន៍នេសាទ ។ បេក្ខជនដែលទទួលបានសន្លឹកឆ្នោតបន្តបន្ទាប់ត្រូវទទួលតួនាទីជាអនុប្រធាន ជាសមាជិកគណៈកម្មការសហគមន៍នេសាទតាមលំដាប់លំដោយ ។ ក្នុងករណីបេក្ខជនដែលមានសំឡេងគាំទ្រស្មើគ្នា ត្រូវជ្រើសរើសស្ត្រី ឬបោះឆ្នោតរកអ្នកដែលមានសមត្ថភាព ដោយលើកដៃយកមតិលើសពីពាក់កណ្តាលនៃចំនួនសមាជិកសហគមន៍នេសាទដែលចូលរួម ។

## ជំពូកទី ៩
## លក្ខខណ្ឌនៃការរំសាយសហគមន៍នេសាទ និង នីតិវិធីដោះស្រាយវិវាទ

**ប្រការ ២៧.-**

ការរំសាយសហគមន៍នេសាទត្រូវផ្អែកតាម ÷

- សំណើរបស់ខណ្ឌរដ្ឋបាលជលផល នៅពេលដែលពិនិត្យឃើញថា មានការរំលោភធ្ងន់ធ្ងរលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- សេចក្តីសម្រេចមហាសន្និបាត

ក្រោយពីរំសាយសហគមន៍នេសាទ ទ្រព្យសម្បត្តិរបស់សហគមន៍ត្រូវចាត់ចែងតាមការអនុម័តរបស់មហាសន្និបាត លើកលែងតែដែននេសាទដែលត្រូវប្រគល់ជូនរដ្ឋវិញ ។

**ប្រការ ២៨.-**

ក្នុងករណីមានការតវ៉ាចោទប្រកាន់ថា ដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទមានភាពមិនប្រក្រតី អ្នកតវ៉ាត្រូវបង្ហាញភស្តុតាងឱ្យបានច្បាស់លាស់អំពីភាពមិនប្រក្រតីនោះភ្លាម នៅមុនពេលប្រកាសលទ្ធផលបោះឆ្នោត ដើម្បីទុកលទ្ធភាពជូនមហាសន្និបាតពិនិត្យ និងសម្រេច ។

**ប្រការ ២៩.-**

វិវាទទាំងឡាយនៅក្នុងសហគមន៍នេសាទ ត្រូវដោះស្រាយដូចខាងក្រោម ÷

- គណៈកម្មការសហគមន៍នេសាទត្រូវសម្រុះសម្រួល និងដោះស្រាយរាល់វិវាទដែលកើតមានឡើងនៅក្នុងសហគមន៍នេសាទរបស់ខ្លួន
- ក្នុងករណីគណៈកម្មការសហគមន៍នេសាទដោះស្រាយវិវាទនោះពុំបានសម្រេច ត្រូវបញ្ជូនសំណុំរឿងនោះទៅសមត្ថកិច្ចរដ្ឋបាលជលផលដើម្បីដោះស្រាយទៅតាមឋានានុក្រម ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធតាមការចាំបាច់ ។
- ក្នុងករណីដែលបញ្ហាវិវាទនោះនៅតែមិនអាចដោះស្រាយបាន គណៈកម្មការសហគមន៍នេសាទ និងរដ្ឋបាលជលផលត្រូវបញ្ជូនសំណុំរឿងទៅតុលាការខេត្ត ក្រុងសាមីដើម្បីដោះស្រាយតាមផ្លូវច្បាប់ ។

**ប្រការ ៣០.-**

សមាជិកសហគមន៍នេសាទរូបណាដែលមិនគោរពតាមលក្ខន្តិកៈសហគមន៍នេសាទនេះ ត្រូវទទួលទណ្ឌកម្មពីគណៈកម្មការសហគមន៍នេសាទ ឬមហាសន្និបាតសហគមន៍នេសាទ ទៅតាមកម្រិតនៃទោសកំហុសរបស់ខ្លួន ។

## ជំពូកទី ១០
## នីតិវិធីនៃការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

**ប្រការ ៣១.-**

ការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទត្រូវសម្រេចដោយមហាសន្និបាត ។ ការលើកសំណើកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទត្រូវធ្វើឡើង ដោយសមាជិកយ៉ាងតិចមួយភាគបី(១/៣) នៃ

សមាជិកសហគមន៍នេសាទទាំងអស់ ហើយសំណើនេះត្រូវដាក់ជូនគណៈកម្មការសហគមន៍នេសាទមួយខែមុនបើកមហាសន្និបាត។ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងនេះអាចកែប្រែបាន លុះត្រាតែមានសំឡេងយល់ព្រមលើសពីពាក់កណ្ដាលនៃសមាជិកមហាសន្និបាតសហគមន៍នេសាទ។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**ប្រការ ៣២.–**

លក្ខន្តិកៈសហគមន៍នេសាទនេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទលើកដំបូង នៅថ្ងៃទី...8...ខែ...11...ឆ្នាំ២០០...6...និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខារបស់ប្រធានគណៈកម្មការសហគមន៍នេសាទ។

ធ្វើនៅ...[illegible]...ថ្ងៃទី...8... ខែ...11...ឆ្នាំ...2006

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

[illegible]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ត្រាំពែរ

## បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

ដើម្បីធានាការគ្រប់គ្រងសហគមន៍នេសាទឱ្យប្រព្រឹត្តទៅមានប្រសិទ្ធភាព និងមានរបៀបរៀបរយល្អ សហគមន៍នេសាទ ត្រាំពែរ សម្រេចដាក់ចេញនូវបទបញ្ជាផ្ទៃក្នុងដូចខាងក្រោម ÷

**ប្រការ ១.–**

គណៈកម្មការ និងសមាជិកសហគមន៍នេសាទគ្រប់រូបត្រូវមានការស្មោះត្រង់ សាមគ្គីឯកភាពផ្ទៃក្នុងជួយស្ថាបនា ព្រមទាំងចូលរួមរៀនសូត្របច្ចេកទេសផ្សេងៗ សម្រាប់បម្រើឱ្យការរីកចម្រើនរបស់សហគមន៍នេសាទ។

**ប្រការ ២.–**

គណៈកម្មការ សមាជិកសហគមន៍នេសាទ ឬបុគ្គលណាដែលបានកេងប្រវ័ញ្ចធ្វើឱ្យខូចខាត ឬបាត់បង់ទ្រព្យសម្បត្តិ និងផលប្រយោជន៍សហគមន៍នេសាទ ត្រូវទទួលទណ្ឌកម្មដូចខាងក្រោមនេះ ÷

- ចំពោះសមាជិកសហគមន៍នេសាទ ឬបុគ្គលដទៃទៀតត្រូវសង ឬទូទាត់ទៅតាមទំហំនៃការខូចខាតជាក់ស្តែង តាមការសម្រេចរបស់អង្គប្រជុំគណៈកម្មការសហគមន៍នេសាទ។ ក្នុងករណីមិនព្រមសង ត្រូវដាក់ជូនមហាសន្និបាតសម្រេច
- ចំពោះគណៈកម្មការសហគមន៍នេសាទត្រូវសង ឬទូទាត់សងការខូចខាតតាមការសម្រេចរបស់មហាសន្និបាត។ ប្រសិនបើនីតិវិធីខាងលើនេះនៅតែមិនអាចដោះស្រាយបាន គឺត្រូវអនុវត្តតាមផ្លូវច្បាប់ និងបទបញ្ជាជាធរមាន។

**ប្រការ ៣ .–**

សមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវតែចូលរួមមហាសន្និបាត និងរាល់កិច្ចប្រជុំរបស់សហគមន៍នេសាទ តាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការសហគមន៍នេសាទ។ ក្នុងករណីដែលសមាជិកសហគមន៍ណាមិនបានមកចូលរួមប្រជុំចំនួន ៣ ដង ជាប់គ្នាដោយគ្មានមូលហេតុច្បាស់លាស់ ត្រូវទទួលការណែនាំពីគណៈកម្មការសហគមន៍នេសាទ។

ករណីនៅតែមិនរាងចាល គណៈកម្មការត្រូវធ្វើសំណើទៅមហាសន្និបាតសម្រេចដើម្បីបញ្ឈប់ពីសមាជិកភាព។

**ប្រការ ៤.–**

សិទ្ធិដាក់ទណ្ឌកម្ម ÷

**ក –គណៈកម្មការសហគមន៍នេសាទ**

- អប់រំណែនាំលើកទី១ លើកទី២ និងលើកទី៣
- ព្រមានផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ
- ព្យួរសមាជិកភាពរបស់សមាជិកសហគមន៍នេសាទ

- បញ្ជូនបញ្ហាទំនាស់ទៅមហាសន្និបាតសម្រេច
- ផ្អាកការនេសាទ ធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅសមត្ថកិច្ចរដ្ឋបាលជលផល ចំពោះការនេសាទលើសទំហំ ចំនួន និងខុសប្រភេទ ពេលវេលា ទីតាំងតាមការកំណត់នៅក្នុងផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងនៅក្នុងកន្លែងនេសាទសហគមន៍។

**៩-មហាសន្និបាត**

- អនុម័តការបណ្តេញចេញដូចមានចែងក្នុងប្រការ ៧ នៃលក្ខន្តិកៈសហគមន៍នេសាទ
- សម្រេចលើសំណងការខូចខាតទ្រព្យសម្បត្តិសហគមន៍នេសាទ
- សម្រេចដាក់ទណ្ឌកម្មដល់គណៈកម្មការ
- ដាក់ទណ្ឌកម្មដល់សមាជិក ឬបុគ្គលដទៃដែលគណៈកម្មការមិនអាចដោះស្រាយបាន។

## ប្រការ ៥.-

សមាជិកសហគមន៍នេសាទគ្រប់រូបត្រូវរាយការណ៍ជូនគណៈកម្មការសហគមន៍នេសាទអំពីសំភារៈ ឧបករណ៍នេសាទ ដែលគ្រួសារនីមួយៗប្រើប្រាស់នៅក្នុងកន្លែងនេសាទសហគមន៍។

## ប្រការ ៦.-

សមាជិកសហគមន៍នេសាទអាចប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារនៅក្នុងរដូវបើកនេសាទ ដូចមានចែងខាងក្រោម÷

| | | |
|---|---|---|
| – មងប្រវែងមិនលើសពី | ១៥០ | ម៉ែត្រ |
| – អួនប្រវែងមិនលើសពី | ៣០ | ម៉ែត្រ |
| – អញ្ចងប្រវែងមិនលើសពី | ៥ | ម៉ែត្រ |
| – ថ្នងទំហំមិនលើសពី | ២ | ម៉ែត្រ |
| – សន្ទូចរនងមិនលើសពី | ៣៥០ | ម៉ែត្រ |
| – សំណាញ់ប្រវែងមិនលើសពី | ៤ | ម៉ែត្រ |
| – លាន់ចំនួនមិនលើសពី | ១០០ | គ្រឿង |
| – ឡើចំនួនមិនលើសពី | ៥ | គ្រឿង |
| – លបចំនួនមិនលើសពី | ៥ | គ្រឿង មុខកាត់ ០,៨០ ម កំពស់ ១,៥ ម ព្រួល ៣ ម ហាមតភ្ជាប់គ្នា |
| – ទ្រូ | ៥ | គ្រឿង |
| – សៃយឺនចំនួនមិនលើសពី | ៥០ | គ្រឿង |
| – ជូចំនួនមិនលើសពី | ៣០ | គ្រឿង |

*<u>សំគាល់:</u>* *ការប្រើប្រាស់ឧបករណ៍នេសាទនេះនឹងមានការកែប្រែបន្ទាប់ពីមានសេចក្តីប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារ។*

**ប្រការ ៧.–**

សមាជិកសហគមន៍នេសាទដែល ÷

- ប្រព្រឹត្តផ្ទុយ ឬរារាំងមិនឱ្យសមាជិកដទៃអនុវត្តសិទ្ធិ និងកាតព្វកិច្ចដូចក្នុងប្រការ ៥ នៃលក្ខន្តិកៈត្រូវព្យួរសមាជិកភាពដោយគណៈកម្មការសហគមន៍នេសាទ ឬបណ្តេញចេញពីសមាជិកភាពដោយមហាសន្និបាត
- មិនចូលរួមថែរក្សាការពារធនធានជលផល ឬមិនរាយការណ៍អំពីសកម្មភាពបទល្មើសជលផលត្រូវព្រមានដោយគណៈកម្មការសហគមន៍នេសាទ
- ប្រើប្រាស់ឧបករណ៍ហាមឃាត់ ធ្វើនេសាទខុសច្បាប់ កាប់ឆ្ការរានព្រៃលិចទឹក ត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ស្តីពីជលផល
- ធ្វើនេសាទក្នុងកន្លែងអភិរក្សរបស់សហគមន៍នេសាទ ត្រូវផ្អាកការនេសាទ ហើយធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលជលផលមានសមត្ថកិច្ច
- អនុវត្តផ្ទុយនឹងបទប្បញ្ញត្តិច្បាប់ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀង ឬផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវផ្អាកការនេសាទ ទទួលការព្រមានជាលាយលក្ខណ៍អក្សរ ធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ជូនទៅរដ្ឋបាលជលផលមានសមត្ថកិច្ចដើម្បីដោះស្រាយតាមច្បាប់។

**ប្រការ ៨.–**

ចំពោះអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទ អាចមានសិទ្ធិចេញចូល និងនេសាទក្នុងកន្លែងនេសាទសហគមន៍ ប៉ុន្តែត្រូវជូនព័ត៌មានដល់គណៈកម្មការសហគមន៍នេសាទ ហើយធ្វើកិច្ចសន្យា និងគោរពកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងជួយឧបត្ថម្ភថវិកាសម្រាប់ការងារគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍសហគមន៍នេសាទ។

ក្នុងករណីដែលអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទ មិនបានគោរពតាមប្រការនេះ គណៈកម្មការសហគមន៍នេសាទមានសិទ្ធិបញ្ឈប់សកម្មភាពនេសាទរបស់ជននោះ ហើយធ្វើការអប់រំ ណែនាំ។

**ប្រការ ៩.–**

បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទលើកដំបូងនៅថ្ងៃទី..8..ខែ..11..ឆ្នាំ២០០..6..និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាដោយប្រធានគណៈកម្មការសហគមន៍នេសាទ។

ធ្វើនៅ...[illegible]...ថ្ងៃទី...8...ខែ...11...ឆ្នាំ...2006

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

# សេចក្តីថ្លែងការណ៍

យើងខ្ញុំជាគណៈកម្មការសហគមន៍នេសាទ ត្រាំពែរ ដែលបានបង្កើតនៅក្នុងឆ្នាំ ២០០១ ក្រោមការឧបត្ថម្ភបច្ចេកទេស ដោយខណ្ឌរដ្ឋបាលជលផល ក្នុងកិច្ចសហការជាមួយមន្ទីរបរិស្ថាន និងកំពុងបន្តការពង្រឹង និងអភិវឌ្ឍន៍សហគមន៍នេសាទ ដោយផ្នែកអនុវត្តគំរោង (PIU) នៃគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប ផ្នែកទី២ ។

យើងខ្ញុំសូមគោរពជំរាបនាយខណ្ឌរដ្ឋបាលជលផលជ្រាបថា ការផ្តួចផ្តើមបង្កើតសហគមន៍នេសាទ នេះបានកើតឡើង ក្រោយពីមានភាពអនាធិបតេយ្យនៃការធ្វើនេសាទខុសច្បាប់, ការកាប់ ឆ្ការ គាស់ រាន ឈូសឆាយព្រៃលិចទឹក, ទំនាស់ដែននេសាទ និង បន្ទាប់ពីមានគោលនយោបាយកែទំរង់វិស័យជលផល របស់រាជរដ្ឋាភិបាល នៅខែ តុលា ឆ្នាំ ២០០០មក ធ្វើអោយប្រជាពលរដ្ឋភូមិត្រាំពែរ ឃុំស្នាមព្រះ ទាំងមូលបានព្រមព្រៀងគ្នាបង្កើត សហគមន៍នេសាទត្រាំពែ នេះឡើង ក្នុងគោលបំណងចូលរួមចំណែកគ្រប់គ្រង ការពារ ប្រើប្រាស់ អភិរក្ស កន្លែងនេសាទសហគមន៍ ។

ចាប់តាំងពីចាប់ផ្តើមបង្កើតសហគមន៍នេសាទក្នុងឆ្នាំ២០០១ រហូតមកដល់សព្វថ្ងៃ សហគមន៍នេសាទយើងខ្ញុំបានខិតខំប្រឹងប្រែងធ្វើការងារសំខាន់ៗជាច្រើនដូចជា ការផ្សព្វផ្សាយដើម្បីបង្កើនការចូលរួម ពីប្រជាជនក្នុងការគ្រប់គ្រងធនធានជលផល ការបង្កើតគណៈកម្មការសហគមន៍នេសាទ ការប្រមូលបាននូវវិភាគទានពីសមាជិកសហគមន៍នេសាទ ដើម្បីដំណើរការផ្សព្វផ្សាយ ការងារយាមល្បាតបង្ក្រាបបទល្មើសនេសាទ ទប់ស្កាត់ការពង្រីកដី កសិកម្មតាមមាត់បឹងធម្មជាតិ បង្កើតកន្លែង អភិរក្ស និងការអភិវឌ្ឍន៍សហគមន៍នេសាទ ។ល ។ ទន្ទឹមនឹងនេះសហគមន៍នេសាទយើងខ្ញុំបានរៀបចំរួចរាល់នូវឯកសារ សំរាប់ការបង្កើតសហគមន៍នេសាទ ដូចដែលមានចែងក្នុងមាត្រា ៧ ជំពូកទី ២ នៃអនុក្រឹត្យស្តីពី ការគ្រប់គ្រងសហគមន៍នេសាទ ដែលរួមមានបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង និងផែនទីកន្លែងនេសាទសហគមន៍ ។

ដោយផ្អែកលើសមិទ្ធិផលដូចបានរៀបរាប់ខាងលើ និងការសំរេចរបស់មហាសន្និបាតដែលបានប្រារព្ធ ធ្វើនៅថ្ងៃទី....8........ ខែ....11........ឆ្នាំ...2006...យើងខ្ញុំគណៈកម្មការតំណាងឱ្យសហគមន៍នេសាទ ត្រាំពែរ សូមគោរពជូននាយខណ្ឌរដ្ឋបាលជលផល នូវកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ដែលមានភ្ជាប់មកជាមួយនូវ បញ្ជីឈ្មោះសមាជិក សហគមន៍នេសាទ លក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ និងផែនទីកន្លែងនេសាទសហគមន៍ ដើម្បីពិនិត្យ និងសំរេចដោយក្តីអនុគ្រោះ ។

យើងខ្ញុំគណៈកម្មការសហគមន៍នេសាទត្រាំពែរ សូមធ្វើការប្តេជ្ញាចិត្ត និងសន្យាថានឹងដឹកនាំក្នុងការគ្រប់គ្រងសហគមន៍នេសាទដោយគោរពទៅតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ និង ច្បាប់លិខិតបទដ្ឋាននានា ដែលទាក់ទងទៅនឹងវិស័យជលផល ។

បើសិនជាយើងខ្ញុំបានប្រព្រឹត្តអ្វីខុសនឹងកិច្ចព្រមព្រៀងខាងលើ យើងខ្ញុំសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ជាធរមាន ។

អាស្រ័យហេតុនេះ សូមនាយខណ្ឌមេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ ។

ធ្វើនៅ [illegible] ថ្ងៃទី 19 ខែ 01 ឆ្នាំ 2007

ប្រធានគណៈកម្មការសហគមន៍នេសាទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ប្រធានគណៈកម្មការសហគមន៍នេសាទត្រាំពែរ**

**សូមគោរពជូន**
**លោកប្រធានការិយាល័យជលផល ខេត្តពោធិ៍សាត់**

**កម្មវត្ថុ** ៖ សំណើ ចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ត្រាំពែរ ។

**យោង** ៖ - អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ លេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០០៧ ។
- សេចក្តីសម្រេចរបស់មហាសន្និបាតសហគមន៍នេសាទ ត្រាំពែរ ដែលបានប្រារព្ធធ្វើឡើង នៅថ្ងៃទី ០៨. ខែវិច្ឆិកា ឆ្នាំ ២០០៦ ។

**លិខិតភ្ជាប់** ៖ កម្មវិធីចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ត្រាំពែរ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធានមេត្តាជ្រាបថា សហគមន៍នេសាទត្រាំពែរបានបង្កើតឡើងនៅឆ្នាំ២០០១ ដោយការស្ម័គ្រចិត្ត និងមានគំនិតផ្តួចផ្តើមបង្កើនជីវភាពរស់នៅរបស់ប្រជានេសាទនៅក្នុងភូមិត្រាំពែរ ឃុំស្នាមព្រះ ដោយមានការសម្របសម្រួលពីការិយាល័យជលផលខេត្តពោធិ៍សាត់ ។ សហគមន៍ត្រាំពែរ មានទីតាំងស្ថិតនៅភូមិត្រាំពែរ ឃុំស្នាមព្រះ ស្រុកបាកាន ខេត្តពោធិ៍សាត់ មានផ្ទៃដី ទំហំ ៣០១៧ ហិកតា ដឹកនាំដោយគណៈកម្មការសហគមន៍នេសាទចំនួន ១១ នាក់ ស្រីចំនួន ០៤ នាក់ សមាជិកសរុប ចំនួន ១៩៨ នាក់ ស្រីចំនួន ៧៥ នាក់ បន្ទាប់ពីបានបង្កើតរួចមក សហគមន៍នេសាទត្រាំពែរ បានដំណើរការការងារយ៉ាងសស្រាក់សស្រាំ ដោយមានការចូលរួមឧបត្ថម្ភគាំទ្រពីគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាបផ្នែកទី២ ស្ថាប័នជំនាញ ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ក្រុមប្រឹក្សាឃុំ និងអង្គការនានា ។ ព្រមជាមួយនោះ គណៈកម្មការ សហគមន៍នេសាទបានរៀបចំ បញ្ជីឈ្មោះសមាជិក លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនទី និងកិច្ចព្រមព្រៀងកន្លែងនេសាទ សហគមន៍រួចជាស្រេច ហើយនឹងគ្រោងរៀបចំកម្មវិធីចុះកិច្ចព្រមព្រៀងសហគមន៍នេសាទ ជាមួយលោកប្រធានការិយាល័យ ជលផលខេត្តពោធិ៍សាត់ ដែលនឹងប្រព្រឹត្តធ្វើ

ឡើងនាថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០០៧ នៅសាលាឃុំស្នាមព្រះ ស្រុកបាកាន ខេត្តពោធិ៍សាត់ ដោយមានការចូលរួមពីសមាជិក សមាជិកាសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ស្ថាប័នពាក់ព័ន្ធ និងក្រុម ប្រឹក្សាឃុំជាសាក្សី ។

សូមជូនភ្ជាប់នកជាមួយនូវ :

១- កិច្ចព្រមព្រៀងសហគមន៍នេសាទ

២- ផែនទីកន្លែងនេសាទសហគមន៍មាត្រដ្ឋាន ១/៥០.០០០

៣- បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ និងគណៈកម្មការសហគមន៍នេសាទ

៤- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង របស់សហគមន៍នេសាទ

៥-សេចក្តីថ្លែងការណ៍ នៃការបង្កើតសហគមន៍នេសាទ ។

អាស្រ័យហេតុនេះ សូមលោកប្រធាន មេត្តាពិនិត្យ និងសម្រេចដោយអនុគ្រោះ ។

ធ្វើនៅ ត្រាំពែរ ថ្ងៃទី...13...ខែ...01...ឆ្នាំ២០០៧

**គណៈកម្មការសហគមន៍នេសាទត្រាំពែរ**

ហត្ថលេខា

ខួល.ឆាត